# តើអ្វីជាថ្នាំប្រូពីលឡាក់ស៊ីស បង្ការជាមុនសម្រាប់ជំងឺ COVID-19?

## ឱសថដែលផលិតឡើងដើម្បីទប់ស្កាត់មិនឱ្យវីរុសតោងជាប់ និងចូលក្នុងកោសិកាមនុស្ស។

### វាការពាររាងកាយពីជំងឺ។



បុគ្គលអាយុ 12 ឆ្នាំឡើងអាចមានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីប្រើថ្នាំប្រូពីលឡាក់ស៊ីសបង្ការជាមុនសម្រាប់បង្ការជំងឺ COVID-19 ប្រសិនបើបុគ្គលនោះ៖

- មានទម្ងន់យ៉ាងហោចណាស់ 88 ផោន (40 kg)។
- បច្ចុប្បន្នមិនបានឆ្លងជំងឺ COVID-19។
- ប្រព័ន្ធភាពស៊ាំចុះខ្សោយពីមធ្យមទៅធ្ងន់ធ្ងរ។
- អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកមិនណែនាំឱ្យចាក់វ៉ាក់សាំងជំងឺ COVID-19។

### តើខ្ញុំអាចទទួលបានថ្នាំប្រូពីលឡាក់ស៊ីសបង្ការជាមុនសម្រាប់ជំងឺ COVID-19 ដែរទេ បើខ្ញុំបានចាក់វ៉ាក់សាំងជំងឺ COVID-19 ថ្មីៗនេះ?

ប្រូពីលឡាក់ស៊ីសបង្ការជាមុនអាចបន្ថយប្រតិកម្មឆ្លើយតបនៃប្រព័ន្ធភាពស៊ាំរបស់អ្នកទៅនឹងវ៉ាក់សាំងជំងឺ COVID-19។ អ្នកគួរតែរង់ចាំយ៉ាងហោចណាស់ពីរសប្តាហ៍ បន្ទាប់ពីចាក់វ៉ាក់សាំងជំងឺ COVID-19 មុនប្រើថ្នាំនេះ។

### តើខ្ញុំប្រើថ្នាំនេះតាមវិធីណា?

អ្នកនឹងចាក់ក្នុងសាច់ដុំ (ចាក់ថ្នាំចូលជ្រៅក្នុងសាច់ដុំ) 2 លើកផ្សេងគ្នា។

### តើការចាក់ថ្នាំនេះត្រូវចំណាយប៉ុន្មាន?

ថ្នាំនេះត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃពីរដ្ឋាភិបាលសហព័ន្ធ។ អ្នកផ្តល់សេវានីមួយៗអាចគិតថ្លៃចាក់ថ្នាំ ដែលនឹងត្រូវទូទាត់វិក្កយបត្រពីអ្នកផ្តល់សេវាធានារ៉ាប់រងរបស់អ្នក ដោយអាចមានការបង់ប្រាក់រួមគ្នាសម្រាប់អ្នកជំងឺ។

Washington State Department of Health

DOH 825-030 March 2022 Khmer
ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមទូរសព្ទទៅលេខ 1-800-525-0127។ អតិថិជនស្តាប់មិនឮ ឬស្តាប់មិនសូវឮ សូមទូរសព្ទទៅលេខ 711 (Washington Relay) ឬផ្ញើអ៊ីមែលទៅ civil.rights@doh.wa.gov។